# សេចក្តីសង្ខេបពីអាជីវកម្ម៖ ការរាយការណ៍

ការរាយការណ៍ ត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងថាជាឧបករណ៍ដ៏សំខាន់មួយនៅក្នុងការទប់ស្កាត់ និងការស៊ើបរកអំពើពុករលួយក៏ដូចជាការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀត។ ការលាតត្រដាងនូវទង្វើមិនត្រឹមត្រូវនៅក្នុងស្ថាប័នមួយ អ្នករាយការណ៍អាចជួយទប់ស្កាត់ និងបង្ហាញអំពើពុករលួយមុនពេលរឿងអាស្រូវនេះបានផ្សព្វផ្សាយជាធារណៈ ហើយទង្វើនេះក៏អាចជួយរក្សាកេរ្តិ៍ឈ្មោះអាជីវកម្ម និងទប់ស្កាត់ការខាតបង់ផ្នែកហិរញ្ញវត្ថុផ្សេងៗ ដែលបណ្តាលមកពីអំពើពុករលួយនេះផងដែរ។ ដោយហេតុថា អំពើពុករលួយមានចរិតលក្ខណៈអាថ៌កំបាំង យើងនឹងមិនអាចដឹងបានឡើយអំពីករណីពុករលួយទាំងនោះ បើសិនជាអ្នកដែលបានដឹងមិនធ្វើការរាយការណ៍។ ប៉ុន្តែការរាយការណ៍ក៏អាចភ្ជាប់ជាមួយនូវផលវិបាកផងដែរសម្រាប់អ្នករាយការណ៍ផ្ទាល់ជាអាទិ៍គឺជាញឹកញាប់អ្នករាយ ការណ៍ស្ថិតនៅចំនុចមួយដែលមានលក្ខណៈប្រឈមនឹងហានិភ័យខ្ពស់ដើម្បីការពារផលប្រយោជន៍ក្រុមហ៊ុន។ ជាលទ្ធផលអ្នករាយការណ៍ អាចប្រឈមនឹងការបាត់បង់ការងារ ប៉ះពាល់ដល់អាជីពនាអនាគត និងអាចមានគ្រោះថ្នាក់ដល់ជីវិតផងដែរ ។ សេចក្តីសង្ខេបអំពីអាជីវកម្មនេះនឹងផ្តល់នូវការពិចារណាមួយសម្រាប់វិស័យឯកជនក្នុងការកសាង គោលនយោបាយស្តីពីការធ្វើសេចក្តីរាយការណ៍សម្រាប់អង្គភាពរបស់ខ្លួន ។

## តើអ្វីទៅជាការរាយការណ៍?

ការរាយការណ៍ គឺជាការលាតត្រដាងនូវព័ត៌មានអំពីការប្រព្រឹត្តខុសនៅក្នុងស្ថាប័នមួយ ឬអំពីហានិភ័យនៃការប្រព្រឹត្តមិនត្រឹមត្រូវដែលជឿជាក់ថានឹងអាចកើតឡើងចំពោះបុគ្គលឬស្ថាប័ន ។ សម្រាប់ក្រុមហ៊ុនអាជីវកម្មគោលដៅសំខាន់បំផុតនៃការរាយការណ៍គឺដើម្បីការពារផលប្រយោជន៍ និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន។ គោលដៅនេះអាចសម្រេចបានតាមរយៈការផ្តល់ព័ត៌មានទៅដល់បុគ្គលឬស្ថាប័នដែលមានតួនាទីក្នុងការធ្វើសកម្មភាពទប់ស្កាត់នូវភាពអន្តរាយ ស៊ើបអង្កេត ឬចាត់វិធានការប្រឆាំងនឹងការប្រព្រឹត្តមិនត្រឹមត្រូវទាំងនោះ[1]។

## តួនាទីរបស់ការរាយការណ៍នៅក្នុងការប្រឆាំងអំពើពុករលួយ

ការរកឲ្យឃើញនូវអំពើពុករលួយ គឺជាការពិបាកហើយជាទូទៅមានតែអ្នកដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តអំពើពុករលួយនិងអ្នកដែលធ្វើការជាមួយពួកគេទាំងនោះតែប៉ុណ្ណោះដែលដឹង។ មានអ្នករាយការណ៍ពីករណីពុករលួយតិចតួចបំផុតនៅក្នុងស្ថាប័ន (ដែលបានកើតឡើងហើយឬក៏កំពុងតែកើតឡើង) ហើយពួកគេក៏ជាអ្នកដែលអាចប្រាប់ឱ្យដឹងពីហានិភ័យនៃការប្រព្រឹត្តមិនត្រឹមត្រូវនៅពេលខាងមុខ។ តាមរយៈការជួយប្រាប់ឲ្យដឹងអំពីអំពើពុករលួយ អ្នករាយការណ៍ដើរតួនាទីដ៏សំខាន់ក្នុងការ បំបែកខ្សែចង្វាក់អាថ៌កំបាំងនៃអំពើពុករលួយឲ្យទៅជាខ្សែចង្វាក់វិជ្ជមាន។ ការស៊ើបរកនូវអំពើពុករលួយនេះ គឺជាបុរេល័ក្ខខ័ណ្ឌនៅក្នុងដំណើរការស៊ើបអង្កេត និងការដាក់ទោស។

---

1 *Policy Position, Transparency International Secretariat 2010*

ទោះជាយ៉ាងណាក៏ដោយ មានតែការស៊ើបអង្កេត ដ៏មានប្រសិទ្ធភាពទៅលើករណីពុករលួយប៉ុណ្ណោះ ដែលអាចផ្លាស់ប្តូរវប្បធម៌ពុករលួយ និងធានាបាននូវសុចរិតភាព។ រឿងអាស្រូវទាក់ទងនឹងអំពើពុករលួយ និងការសូកប៉ាន់ធំៗ បង្ហាញអំពីការខូចខាតដែលបង្កឡើង ដោយសារភាពបរាជ័យក្នុងការរាយការណ៍ភ្លាមៗពីការប្រព្រឹត្តមិនត្រឹមត្រូវដែលបានរកឃើញ។ ភាពព្រងើយកន្តើយ ការភ័យខ្លាចក្នុងការផ្ចាញ់ផ្ចាល និងភាពស្មោះត្រង់ខ្លាំងជ្រុល ដូចជាវប្បធម៌នៃការនៅស្ងៀម ជាទូទៅគឺជាកត្តា រាំងសាក្សី និងអ្នករាយការណ៍ក្នុងការនិយាយចេញមកក្រៅ[2]។

## ការរាយការណ៍នៅក្នុងច្បាប់ប្រឆាំងអំពើពុករលួយនៅកម្ពុជា

នៅក្នុងមាត្រាទី១៣ នៃច្បាប់ប្រឆាំងអំពើពុករលួយបានចែងពីភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការចាត់វិធានការចាំបាច់ ដើម្បីរក្សាសុវត្ថិភាពរបស់បុគ្គលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ។ ប៉ុន្តែនៅក្នុងមាត្រាទី៤១នៃច្បាប់ដដែលនេះចែងថា អ្នករាយការណ៍ភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការអំពីអង្គហេតុបទល្មើសពុករលួយដែលនាំអោយអង្គភាពធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ នឹងត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី១០០០០០(មួយសែន)រៀលទៅ១០០០០០០(មួយលាន)រៀល[3] ។ ដើម្បីលើកទឹកចិត្តឲ្យមានការរាយការណ៍ពីអំពើពុករលួយរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសនូវផែនការពង្រាងច្បាប់ការពារអ្នករាយការណ៍ពីអំពើពុករលួយ។

អង្គការតម្លាភាពកម្ពុជាបានចេញផ្សាយនូវសេចក្តីសង្ខេបនយោបាយស្តីពី"សារៈសំខាន់នៃច្បាប់ការពារសាក្សី និងអ្នករាយការណ៍នៅក្នុងប្រទេសកម្ពុជា"នៅក្នុងខែមករាឆ្នាំ២០១៦។ រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មការទី១០នៃរដ្ឋសភាក៏បានបង្ហាញពីការប្តេជ្ញារួមគ្នាក្នុងការពង្រាងច្បាប់ការពារអ្នករាយការណ៍នេះផងដែរ ។

## តើគោលនយោបាយដូចម្តេចចាត់ទុកជាគោលនយោបាយ និងទម្រង់បែបបទល្អសម្រាប់ក្រុមហ៊ុនអាជីវកម្ម ក្នុងការការពារអ្នករាយការណ៍?

គោលនយោបាយការពារអ្នករាយការណ៍ពីអំពើពុករលួយ គួររៀបចំឡើងដើម្បីលើកទឹកចិត្តដល់បុគ្គលិកឲ្យហ៊ាននិយាយចេញមកក្រៅបើសិនជាពួកគេមានក្តីបារម្ភសមហេតុផលអំពីការប្រព្រឹត្តមិនត្រឹមត្រូវណាមួយ ហើយមិនពាក់ព័ន្ធនឹងករណីបណ្តឹងផ្ទាល់ខ្លួនរបស់បុគ្គល ។ គោលនយោបាយនេះក៏ គួរតែបង្កើតនូវទម្រង់បែបបទមួយ ដែលអាចឈានដល់ការអនុវត្តនូវគោលនយោបាយនេះ។ គោលនយោបាយទាំងនេះ អាចរៀបចំឡើងដាច់ដោយឡែក ឬក៏ជាផ្នែកមួយនៅក្នុងក្រមសីលធម៌។ គោលនយោបាយការពារអ្នករាយការណ៍ដែលល្អគួរតែ:

- មានលក្ខណៈសាមញ្ញ និងងាយស្រួលយល់
- គ្របដណ្តប់ទំហំការងារកាន់តែច្រើនកាន់តែល្អ កំណត់ឲ្យច្បាស់នូវបទដ្ឋាន (ស្តង់ដា) នៃអាកប្បកិរិយាដែលរំពឹងទុកពីបុគ្គលិក
- កំណត់អោយច្បាស់ថាព័ត៌មានអ្វីខ្លះត្រូវប្រកាស ឬទង្វើអ្វីខ្លះចាត់ជាការប្រព្រឹត្តមិនត្រឹមត្រូវ កំណត់អោយច្បាស់នូវរបៀប ឬមធ្យោបាយ និងអ្នក ដែលត្រូវទៅរកនៅពេលមានកង្វល់ផ្សេងៗ (រួម បញ្ចូលទាំងព័ត៌មានទំនាក់ទំនងលម្អិត)

[2] Policy Position, Transparency International Secretariat 2010
[3] *Cambodian Anti-Corruption Law 2010*

- អនុញ្ញាតឲ្យបុគ្គលិកជៀសពីបុគ្គល ឬផ្នែកណាមួយនៃអាជីវកម្មដែលជាប់ពាក់ព័ន្ធនឹងក្តីបារម្ភ។ ស្ថាប័នជាច្រើនមានលេខទំនាក់ទំនងប្រចាំ (ហតឡាញ) សម្រាប់ការរាយការណ៍សម្ងាត់ ដើម្បីធានាឲ្យបុគ្គលិកមានអារម្មណ៍ទុកចិត្ត និង ងាយស្រួលក្នុងការផ្តល់ព័ត៌មាន និងផ្តល់ដល់ អ្នករាយការណ៍នូវចំណុចសំខាន់ៗនៃនីតិវិធី បន្ទាប់កំណត់វិធានការស៊ើបអង្កេតនូវរាល់បញ្ហា បារម្ភ និងចំណាត់ការចំពោះការប្រព្រឹត្តខុស
- បង្កើតនូវគោលនយោបាយការពារដែលលើកទឹកចិត្តដល់អ្នករាយការណ៍ដែលមានសច្ចៈភាព

អ្នកមានក្តីបារម្ភ ឬបញ្ហាពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មដែលមិនត្រឹមត្រូវ ទុច្ចរិត ឬខុសច្បាប់

ពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់របស់អ្នក ឬប្រធានផ្នែក /នាយកដ្ឋាន

ប្រសិនបើក្តីបារម្ភនោះមានមូនដ្ឋានគ្រប់គ្រាន់ អ្នកគ្រប់គ្រងផ្ទាល់ឬប្រធានផ្នែក/នាយកដ្ឋាន ប្រាប់ទៅបុគ្គលទទួលបន្ទុកគ្រប់គ្រងហានិភ័យផ្ទៃក្នុង

ប្រសិនបើក្តីបារម្ភនោះមានមូលដ្ឋានគ្រប់គ្រាន់ អ្នកគ្រប់គ្រងផ្ទាល់ឬប្រធានផ្នែក/នាយកដ្ឋាន ប្រាប់ទៅបុគ្គលទទួលបន្ទុកគ្រប់គ្រងហានិភ័យផ្ទៃក្នុង និងបុគ្គលទទួលខុសត្រូវកត់ត្រាបញ្ហាផ្ទៃក្នុង

[4] ប្រធានគ្រប់គ្រងហានិភ័យ ឬប្រធានគ្រប់គ្រងធនធានមនុស្សពិចារណាអំពីភាពចាំបាច់ក្នុងការពិភាក្សាជាមួយម្ចាស់ក្រុមហ៊ុន ដៃគូក្រុមហ៊ុន ឬនាយកនិង/ ឬម្ចាស់ភាគហ៊ុនធំៗ ម្ចាស់ក្រុមហ៊ុន ដៃគូក្រុមហ៊ុន ឬនាយក និង/ឬម្ចាស់ភាគហ៊ុនធំៗពិនិត្យកំណត់ត្រា

## ហេតុអ្វីបានជាអាជីវកម្មត្រូវមានគោលនយោបាយការពារអ្នករាយការណ៍?

សរុបសេចក្តីមក គោលនយោបាយការពារអ្នករាយការណ៍គឺជាសមាសភាពដ៏ចាំបាច់មួយសម្រាប់ស្ថាប័ន ។ បើគ្មានគោលនយោបាយនេះទេនោះ ការគៃបន្លំការប្រព្រឹត្តខុសនិងភាពបរាជ័យនឹងអាចកើតមាន ដែលអាចធ្វើឲ្យក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះមិនល្អ និងទទួលរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង។ តាមរយៈការពង្រឹងការទំនាក់ទំនងច្បាស់លាស់ដោយ ផ្តោតការយកចិត្តទុកដាក់ទៅលើគោលដៅរបស់ ក្រុមហ៊ុនទាំងមូល ក្រុមហ៊ុនប្រាកដជាអាចកាត់បន្ថយ នូវឱកាសក្នុងការឈានទៅរកគ្រោះមហន្តរាយ។ ដោយមានការកំណត់ច្បាស់លាស់ពីថ្នាក់គ្រប់គ្រង ជាន់ខ្ពស់ គោលនយោបាយ និងទម្រង់បែបបទនៃការ ការពារអ្នករាយការណ៍ច្បាស់លាស់ គឺជាគន្លឹះសំខាន់ ក្នុងការកសាងវប្បធម៌សុចរិតភាពនៅក្នុងអាជីវកម្ម និងការផ្តល់សិទ្ធិអំណាចឲ្យបុគ្គលិកហ៊ាននិយាយ ។

សម្រាប់ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយការពារអ្នករាយការណ៍ សូមទំនាក់ទំនង matsstridsman@ticambodia.org.

[4] *Policy Position, Transparency International Secretariat 2010*